**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

គោលបំណងនៃអនុក្រឹត្យនេះ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

## ជំពូកទី ២

## រចនាសម្ព័ន្ធ

**មាត្រា២ .-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មាន៦ផ្នែកជាជំនួយការ :

-ផ្នែកបច្ចេកទេសវាស់វែង

-ផ្នែកដោះស្រាយបាតុភាព តាមបណ្តោយព្រំដែន

-ផ្នែកអភិវឌ្ឍន៍តាមបណ្តោយព្រំដែន

-ផ្នែកនីតិកម្ម

-ផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងផែនទី

-ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច

អង្គការលេខរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣

## តួនាទី និងភារកិច្ច

**មាត្រា៣ .-**

លេខាធិការ របស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានតួនាទី និងភារកិច្ចដូចតទៅ :

-សម្របសម្រួលកិច្ចការរវាងគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេស និងគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយខ្សែព្រំដែន

-ទទួលបន្ទុកផ្នែករដ្ឋបាល និងហិរញ្ញកិច្ច

-សម្របសម្រួលដំណើរការទូទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍

-សម្របសម្រួលកិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំទ្វេភាគីជាមួយប្រទេសជិតខាង ព្រមទាំងធ្វើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំទាំងនោះ ហើយធ្វើសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ដើម្បីធ្វើរបាយការណ៍ជូនប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៤ .-**

ផ្នែកបច្ចេកទេសវាស់វែង មានតួនាទី និងភារកិច្ច ដូចតទៅ :

-រៀបចំគម្រោងផែនការមេ និងផែនការសកម្មភាពជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច

-អនុវត្តផែនការមេ និងផែនការសកម្មភាព ក្នុងការខ័ណ្ឌសីមា បោះបង្គោលព្រំដែន

-ចូលរួមក្នុងកិច្ចប្រជុំទ្វេភាគី ជាមួយប្រទេសជិតខាង

-សិក្សាស្រាវជ្រាវបច្ចេកទេស និងឧបករណ៍វាស់វែងគ្រប់ប្រភេទ

-ចងក្រងឯកសារបច្ចេកទេស និងលទ្ធផលវាស់វែងព្រំដែនគោក និងព្រំដែនសមុទ្រ

-ចូលរួមក្នុងការកសាងផែនទីព្រំដែន តាមរូបថតអាកាស

-សហការជាមួយនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីបច្ចេកទេសវាស់វែងព្រំដែន

-ចុះអនុវត្តលើដីជាក់ស្តែង ក្នុងការកំណត់ខ្សែព្រំដែន ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ជាមួយប្រទេសជិតខាង

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែកតាមកាលកំណត់ ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៥ .-**

ផ្នែកដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវតំបន់ដែលមានវិវាទ និងបាតុភាពកើតឡើង និងធ្វើរបាយការណ៍អំពីលទ្ធផល ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-ចូលរួមសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យខ្សែបន្ទាត់ព្រំដែន

-សហការជាមួយផ្នែកនីតិកម្ម និងផ្នែកបច្ចេកទេសវាស់វែងក្នុងការដោះស្រាយបាតុភាពនានា នៅតំបន់ព្រំដែន

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែកតាមកាលកំណត់ ជូនប្រធានលេខាធិការដ្ឋាន អចិន្ត្រៃយ៍

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៦ .-**

ផ្នែកអភិវឌ្ឍន៍តាមបណ្តោយព្រំដែន មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវបទពិសោធន៍ក្នុងកិច្ចអភិវឌ្ឍតាមបណ្តោយព្រំដែន ពីបណ្តាប្រទេសនានាដើម្បី កសាងសេចក្តីព្រាងប្លង់មេ ក្នុងកិច្ចអភិវឌ្ឍតាមបណ្តោយព្រំដែន

-លើកគម្រោងជាក់ស្តែងក្នុងការអភិវឌ្ឍន៍តំបន់ព្រំដែន

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែកតាមកាលកំណត់

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៧ .-**

ផ្នែកនីតិកម្ម មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ និងចងក្រងឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែនគោក និងព្រំដែនសមុទ្រ

-ចូលរួមក្នុងការចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ខ្សែបន្ទាត់ព្រំដែន ខណ្ឌសីមា និងបោះបង្គោលព្រំដែន ធ្វើកំណត់ហេតុនៃអង្គប្រជុំ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃអង្គប្រជុំ ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-រៀបចំសេចក្តីព្រាងសន្ធិសញ្ញាព្រំដែនស្ថាពរមួយជាមួយប្រទេសជិតខាង បន្ទាប់ពីការខណ្ឌសីមា បោះបង្គោលព្រំដែនចប់សព្វគ្រប់ ដើម្បីដាក់ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែកតាមកាលកំណត់ ជូនប្រធានលេខាធិការដ្ឋាន អចិន្ត្រៃយ៍

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៨ .-**

ផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងផែនទី មានតួនាទី និងភារកិច្ចដូចតទៅ :

-ស្រង់ និងប្រមូលព័ត៌មានភូមិសាស្ត្រនៅលើដីជាក់ស្តែង

-រៀបចំចងក្រង ប្រមូលទិន្នន័យដើម្បីផលិត និងបោះពុម្ពផែនទីព្រំដែន

-ប្រមូលផ្តុំប្រព័ន្ធព័ត៌មានទាំងលើឯកសារ និងលើដីជាក់ស្តែង សម្រាប់កសាងផែនទីព្រំដែន

-ចូលរួមជាមួយផ្នែកដែលពាក់ព័ន្ធ ក្នុងការកសាងផែនទីព្រំដែនតាមរូបថតអាកាស

-ទទួលគ្រប់គ្រង និងថែរក្សាសម្ភារៈ ឯកសារផែនទីព្រំដែន

-សហការជាមួយនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីបច្ចេកទេសកសាងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងផែនទីព្រំដែន

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែក តាមកាលកំណត់ ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា៩ .-**

ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច មានតួនាទី និងភារកិច្ច ដូចតទៅ :

-ធានាប្រសិទ្ធភាពនូវដំណើរការរដ្ឋបាលទូទៅ

-គ្រប់គ្រង និងចរាចរលិខិតឯកសារឱ្យបានទាន់ពេលវេលា

-គ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ និងរៀបចំវគ្គសិក្សាក្រឹតការឱ្យមន្ត្រីបច្ចេកទេសព្រំដែន

-រៀបចំកិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំទ្វេភាគីជាមួយប្រទេសជិតខាង

-គ្រប់គ្រងទ្រព្យសម្បត្តិ និងឧបករណ៍សម្ភារៈផ្សេងៗ

-រៀបចំគម្រោង និងគ្រប់គ្រងចំណូល-ចំណាយថវិកាជាប្រចាំ

-តាមដាន និងធ្វើរបាយការណ៍រាល់ប្រតិបត្តិការហិរញ្ញវត្ថុ

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ផ្នែកតាមកាលកំណត់ ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ឱ្យ ។

**មាត្រា១០ .-**

ផ្នែកនិមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ផ្នែកទាំងនេះត្រូវមានក្រុមការងារមួយចំនួនជាជំនួយការ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និងប្រធានស្ថាប័ន ព្រមទាំងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ខែសីហា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សុខ អាន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៦**

**អង្គការលេខរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍**

**នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន**

